# របាយការណ៍

# សិក្ខាសាលារៀបចំឯកសារបណ្តុះបណ្តាល
# ស្តីពី
# ការបង្ការការចម្លងរោគនៅក្នុងសេវាព្យាបាល
# ជំងឺអេដស៍ក្នុងបរិបទជំងឺកូវីដជាសកល

## Workshop to Develop Training Materials On
## Infection Prevention and Control at ART sites amid COVID-19
## Pandemic

ថ្ងៃចន្ទ ១២រោច ដល់ថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ត្រូវនឹងថ្ងៃទី២៨ ខែ កុម្ភៈ ដល់ ០២ ខែ មីនា ឆ្នាំ២០២២/ 28 February - 02 March, 2022
នៅភូមិគ្រឹះនាងគង្ហីង ខេត្តកំពង់ចាម / Neang Kong Hing Village, Kampong Cham Province





**រៀបចំដោយ**

**ឧបត្ថម្ភដោយ**

US CDC Cambodia

# របាយការណ៍
# សិក្ខាសាលារៀបចំឯកសារបណ្តុះបណ្តាល
# ស្តីពី
# ការបង្ការការចម្លងរោគនៅក្នុងសេវាព្យាបាលជំងឺអេដស៍
# ក្នុងបរិបទជំងឺកូវីដជាសកល

## Workshop to Develop Training Materials On Infection Prevention and Control at ART sites amid COVID-19 Pandemic

**១. គោលបំណង៖**

- ពិនិត្យមើល និងពិភាក្សាពីលទ្ធផលដែលទទួលបានពីការវាយតម្លៃដើមគ្រាស្តីពី ការអនុវត្តការបង្ការការចម្លងរោគនៅក្នុងសេវាព្យាបាលជំងឺអេដស៍ក្នុងបរិបទកូវីដ១៩
- ពិនិត្យមើលឯកសារបណ្តុះបណ្តាលស្តីពី ការបង្ការការចម្លងរោគដែលមាននៅថ្នាក់ជាតិ និងសម្របសម្រួលឯកសារបណ្តុះបណ្តាលនេះឲ្យសមស្របសម្រាប់កសាងសមត្ថភាពក្រុមការងារនៃសេវាថែទាំ និងព្យាបាលជំងឺអេដស៍នៅមន្ទីរពេទ្យបង្អែកខេត្ត/ស្រុក ក្នុងការអនុវត្តវិធានការបង្ការការចម្លងរោគ ជាពិសេសនៅក្នុងសេវាARTក្នុងបរិបទជំងឺកូវីដ១៩
- ពិភាក្សាអំពី ឯកសារបណ្តុះបណ្តាល និងការបង្កើតសម្ភារអប់រំ និងជំហ៊ានបន្ទាប់។

**២. លទ្ធផល**





នាថ្ងៃទី ២៨ កុម្ភៈ ដល់ ០២ ខែ មីនា ឆ្នាំ ២០២២ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានរៀបចំវគ្គសិក្ខាសាលារៀបចំឯកសារបណ្តុះបណ្តាលស្តីពី ការបង្ការការចម្លងរោគនៅក្នុងសេវាព្យាបាលជំងឺអេដស៍ ក្នុងបរិបទកូវីដ-១៩ជាសកល ក្រោមការឧបត្ថមថវិកា US-CDS Cambodia នៅភូមិគ្រឹះនាងគង្ហីង ខេត្តកំពង់ចាម។

វគ្គសិក្ខានេះក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ លោកវេជ្ជ. អ៊ុក វិជ្ជា ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ លោកវេជ្ជ. សេង សុផារ៉ុន អនុប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ចាម និងលោកវេជ្ជ. លី វណ្ណធី តំណាង US CDC Cambodia រួម



ជាមួយអ្នកចូលរួមជា ប្រធាន/អនុប្រធានមន្ទីរសុខាភិបាលខេត្ត អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ប្រធានការិយាល័យបច្ចេកទេស នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ តំណាងស្ថាប័នម្ចាស់ជំនួយ អង្គការពាក់ព័ន្ធនានាមកពីរាជធានីខេត្ត។






